វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៨១អនក្រ .បក/ថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០០១

# អនុក្រឹត្យស្តីពីការកាត់ផ្ទៃដីក្រហមពីដែនព្រៃសម្បទានសំរាប់ចំការកៅស៊ូ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៥ ក្រច ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

មាត្រា ១:

ត្រូវបានកាត់ផ្ទៃដីក្រហមចំនួន ៦.២០០ ហិកតា ចេញពីដែនព្រៃសម្បទានដែលក្នុងនោះផ្ទៃដីរបស់ក្រុមហ៊ុនហ្កេតចំនួន ២.១៨១ ហិកតា សហគ្រាសកូឡិចស៊ីមចំនួន ៣.៥៧៧ ហិកតា និងក្រុមហ៊ុន មៀង លីហេងចំនួន ៤៤២ ហិកតា ដែលស្ថិតនៅ ក្នុងឃុំទីរឹង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ដូចមានផែនទីបញ្ជាក់ទីតាំងជាឧបសម្ព័ន្ធជូនភ្ជាប់ ។

មាត្រា ២ :

ដីក្រហមនេះត្រូវប្រគល់អោយ :

- ប្រជាជនកំពុងកាន់កាប់ចំនួន ៩១២ ហិកតា
- ទុកបំរុងចែកជូនប្រជាជនសំរាប់ដាំកៅស៊ូជាលក្ខណៈគ្រួសារចំនួន ៩២៩ ហិកតា ។
- ចំការកៅស៊ូជុប សំរាប់ដាំកៅស៊ូជាលក្ខណៈឧស្សាហកម្មចំនួន ៤.៣៥៩ហិកតា ។

មាត្រា ៣ :

ចំការកៅស៊ូជុប មានភារកិច្ចផ្តល់ជូនប្រជាជននូវ សេវាបច្ចេកទេស ក្នុងការដាំដុះ ការថែទាំរហូតដល់ពេលប្រមូលផល ។

មាត្រា ៤ :

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើការវាស់វែងដាក់ស្លែង និង រៀបចំធ្វើកម្មសិទ្ធិកាន់កាប់ដីធ្លីជូនប្រជាជន និង ចំការកៅស៊ូជុប ។

មាត្រា ៥:

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

មាត្រា ៦:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។